- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤២ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនសមាជិក សមាជិកា សហគមន៍ជនជាតិដើមភាគតិច ចំនួន ២៥ រូប ដែលមានស្នាដៃល្អក្នុងការចូលរួមអនុវត្តគំរោងចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចសាកល្បង និងគណៈកម្មាធិការសហគមន៍ ជនជាតិដើមភាគតិច នៃភូមិគោលដៅសាកល្បងទាំង០៣ (០២ភូមិក្នុងខេត្តរតនគីរី និង០១ភូមិ ក្នុងខេត្តមណ្ឌលគីរី) ដូចមានរាយនាមខាងក្រោម ៖

១-	លោក យ៉ាន់ ធឿន	សមាជិកសហគមន៍ជនជាតិទំពួន ភូមិល្មីនក្រែន ខេត្តរតនគីរី
២-	លោក ហាយ កិត	សមាជិកសហគមន៍ជនជាតិទំពួន ភូមិល្មីនក្រែន ខេត្តរតនគីរី
៣-	អ្នកស្រី មាំង អិន	សមាជិកាសហគមន៍ជនជាតិទំពួន ភូមិល្មីនក្រែន ខេត្តរតនគីរី
៤-	លោក ធិល ផល់	សមាជិកសហគមន៍ជនជាតិទំពួន ភូមិល្មីនក្រែន ខេត្តរតនគីរី
៥-	លោក ងើង ធិន	សមាជិកសហគមន៍ជនជាតិទំពួន ភូមិល្មីនក្រែន ខេត្តរតនគីរី
៦-	លោក ម៉ូត ថែន	សមាជិកសហគមន៍ជនជាតិទំពួន ភូមិល្មីនក្រែន ខេត្តរតនគីរី
៧-	លោក ភាំង ធុន	សមាជិកសហគមន៍ជនជាតិទំពួន ភូមិល្មីនក្រែន ខេត្តរតនគីរី
៨-	លោក ព្រុយ លី	សមាជិកសហគមន៍ជនជាតិទំពួន ភូមិល្មីនក្រែន ខេត្តរតនគីរី

៩-	លោក មឿង ងឹក	សមាជិកសហគមន៍ជនជាតិទំពួន ភូមិឡាអ៊ិន ខេត្តរតនគិរី
១០-	លោក រី វ៉ាន	សមាជិកសហគមន៍ជនជាតិទំពួន ភូមិឡាអ៊ិន ខេត្តរតនគិរី
១១-	លោក ឡឹង បា	សមាជិកសហគមន៍ជនជាតិទំពួន ភូមិឡាអ៊ិន ខេត្តរតនគិរី
១២-	លោក ហៀវ ញឿន	សមាជិកសហគមន៍ជនជាតិទំពួន ភូមិឡាអ៊ិន ខេត្តរតនគិរី
១៣-	លោក ប៊ីន ភី	សមាជិកសហគមន៍ជនជាតិទំពួន ភូមិឡាអ៊ិន ខេត្តរតនគិរី
១៤-	អ្នកស្រី ជត់ ព្រល	សមាជិកាសហគមន៍ជនជាតិទំពួន ភូមិឡាអ៊ិន ខេត្តរតនគិរី
១៥-	លោក ពក សាឡុន	សមាជិកសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
១៦-	លោក ហើយ ស្រូប	សមាជិកសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
១៧-	លោក មួយ ញ៉ូវ	សមាជិកសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
១៨-	លោក អើយ វ៉ាន់	សមាជិកសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
១៩-	លោក ភី តេល	សមាជិកសហគមន៍ជនជាតិព្នងភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
២០-	លោក ច្រាង គិមថេង	សមាជិកសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
២១-	លោក ផ្សល់ ណើយ	សមាជិកសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
២២-	អ្នកស្រី ឡើត កេន	សមាជិកាសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
២៣-	អ្នកស្រី ឃ្លើវ កឿត	សមាជិកាសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
២៤-	អ្នកស្រី បោះ ពេ	សមាជិកាសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី
២៥-	លោក ណាវ៉ាន់ ពួម	សមាជិកសហគមន៍ជនជាតិព្នង ភូមិអណ្តូងក្រឡឹង ខេត្តមណ្ឌលគិរី

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៤៣.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសុវត្ថារា** តាមលំដាប់ថ្នាក់ ជូនក្រុមការងារអន្តរស្ថាប័ន មន្ត្រីជំនាញបច្ចេកទេសថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុក ឃុំ ភូមិ សមាជិកសហគមន៍ តំណាងដៃគូអភិវឌ្ឍន៍ និងបុគ្គលិកអង្គការអន្តរជាតិ ចំនួន៧០រូប ដែលមានស្នាដៃល្អក្នុងការអនុវត្តគំរោងចុះបញ្ជីដីសហគមន៍ជនជាតិដើមភាគតិចសាកល្បង និងគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិច នៃភូមិគោលដៅសាកល្បងទាំង០៣ (០២ភូមិក្នុងខេត្តរតនគីរី និង០១ភូមិ ក្នុងខេត្តមណ្ឌលគីរី) ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ:

១-	ឯកឧត្តម អេង ប៊ុនហៀង	ប្រធានក្រុមប្រឹក្សា ខេត្តមណ្ឌលគីរី
២-	លោក ឡោ ដារ៉ុថ	ប្រធាននាយកដ្ឋានបច្ចេកទេសក្រសួង ដនស
៣-	ឯកឧត្តម ជ័យ សាយឿន	សមាជិកក្រុមប្រឹក្សា ខេត្តរតនគីរី
៤-	លោកស្រី អាយស៊ី សុគន្ធារី	អភិបាលរង នៃគណៈអភិបាលខេត្តមណ្ឌលគីរី
៥-	លោក ឃុន សមណា	អនុប្រធានមន្ទីរ ដនសស ខេត្តមណ្ឌលគីរី
៦-	លោក ទឹម មុនីរតន្ត័	អនុប្រធានមន្ទីរ ដនសស ខេត្តរតនគីរី
៧-	លោក អ៊ុក សម្បត្តិ	អនុប្រធានមន្ទីរ ដនសស ខេត្តរតនគីរី
៨-	លោក ឌុយ ផេង	ទីប្រឹក្សា អគ្គ/ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
៩-	លោក ផន ស៊ីន	ទីប្រឹក្សាអគ្គ/ក្រុមប្រឹក្សាគោលនយោបាយដីធ្លី

ខ-មេដាយសុវត្ថារា ថ្នាក់ សេនា:

១- លោក ជា សំអាង អនុប្រធានរដ្ឋបាលព្រៃឈើ ក្រសួង កសិ.រុក្ខា.នេសាទ
២- លោកស្រី អ៊ុក សីហា អគ្គនាយករង ក្រសួងបរិស្ថាន
៣- លោក កុសល សុពិនត្ស ប្រធាននាយកដ្ឋាន ក្រសួង ដនស
៤- លោក សុត សឿង អនុប្រធាននាយកដ្ឋាន ក្រសួងអភិវឌ្ឍន៍ជនបទ
៥- លោក មាស សុង ប្រធានការិយាល័យក្រសួង ដនស
៦- លោក គៀង ហាក់ អនុប្រធានការិយាល័យក្រសួង ដនស
៧- លោក សួង យុទ្ធីរក្ស អនុប្រធានការិយាល័យក្រសួង ដនស
៨- លោក ហ៊ឹង ម៉ៅសំអាត អនុប្រធានការិយាល័យក្រសួង ដនស
៩- លោក ស្រុង ជុំ ប្រធានផ្នែកគណនា ក្រសួង ដនស
១០- លោក ស៊ាង សុងដួ ប្រធានផ្នែកព័ត៌មានវិទ្យាក្រសួង ដនស
១១- លោក ខៀវ សុភ័ក្ស ប្រធានគំរោងអភិវឌ្ឍន៍ សហគមន៍ចំរុះអង្គការ DPA
១២- លោក បៀន ធ្វើន ប្រធានក្រុមប្រឹក្សាស្រុកអូរជុំ- ខេត្តរតនគិរី
១៣- លោក អ៊ិន ណុប ប្រធានក្រុមប្រឹក្សាស្រុក កូនមុំ-ខេត្តរតនគិរី
១៤- លោក ប៉ែន ភក្ត្រា មន្ត្រីការិយាល័យ សហគមន៍ព្រៃឈើ រដ្ឋបាលព្រៃឈើ
១៥- លោក អ៊ុត សារឿន មេឃុំសែនមនោរម្យ អូររាំង-មណ្ឌលគិរី
១៦- លោក ឡាវ សេដ្ឋាផល ប្រធានការិយាល័យ រដ្ឋបាលព្រៃឈើ
១៧- លោក ប៉ូច សោភ័ណ មន្ត្រីជំនួយបច្ចេកទេស GTZ-LASSP
១៨- លោកម៉ែន សូរិយន់ ប្រធានកម្មវិធីព្រៃការពារ និងអភិរក្សចំរុះ សីមា ខេត្តមណ្ឌលគិរី
១៩- លោក សេក សោភ័ណ ប្រធានគំរោងគាំទ្រជន ជាតិដើមភាគតិច ILO
២០- លោក ជា ផល្លា មន្ត្រីគំរោងគាំទ្រជនជាតិ ដើមភាគតិច ILO
២១- លោក ចាម៉ៅ ផាង មេឃុំតឺន-ស្រុកកូនមុំ ខេត្តរតនគិរី
២២- លោក វ៉ង់ ដួង មេឃុំអូរជុំ-ស្រុកអូរជុំ ខេត្តរតនគិរី

គ-មេដាយសុវត្ថារា ថ្នាក់ អស្សរិទ្ធិ:

១- លោក សោ អៀង ប្រធានការិយាល័យ ដនសភ ខេត្តរតនគិរី
២- លោក មួង ស៊ីថេន មន្ត្រីការិយាល័យ ដនសភ ខេត្តរតនគិរី
៣- លោក ស៊ិត សារេត មន្ត្រីការិយាល័យ ដនសភ ខេត្តរតនគិរី
៤- លោកង៉ែត ញិច មន្ត្រីការិយាល័យ ដនសភ ខេត្តរតនគិរី
៥- លោក ម៉ៅ សារិទ្ធ មន្ត្រីការិយាល័យ ដនសភ ខេត្តរតនគិរី
៦- លោក ប៊ុន ចាន់ថន មន្ត្រីការិយាល័យ ដនសភ ខេត្តរតនគិរី
៧- លោក កែន ជឿន ប្រធានការិយាល័យ ដនសភ ខេត្តរតនគិរី
៨- លោក សយ សុខហឿន ប្រធានការិយាល័យ ដនសភ ខេត្តរតនគិរី
៩- លោក ប៊ី ជីវ៉នតារា ប្រធានការិយាល័យ ដនសភ ខេត្តរតនគិរី
១០- លោកឈឿន ចាន់ធាង អភិបាលស្រុកកូនមុំ ខេត្តរតនគិរី
១១- លោក សាក់ សុន ប្រធានក្រុមប្រឹក្សាស្រុកកូនមុំ-រតនគិរី
១២- លោកហុង វណ្ណារាន នាយសង្កាត់រដ្ឋបាលព្រៃឈើស្រុកអូរជុំ ខេត្តរតនគិរី
១៣- លោក ឥន្ទ សាមិន នាយសង្កាត់រដ្ឋបាលព្រៃឈើស្រុកអូរជុំ ខេត្តរតនគិរី
១៤- លោក ស៊ីន តូតុលា នាយសង្កាត់រដ្ឋបាលព្រៃឈើស្រុកកូនមុំ ខេត្តរតនគិរី
១៥- លោក ខាំ ប៉ៃសាំង ប្រធានការិ.កសិកម្មស្រុកកកូនមុំ ខេត្តរតនគិរី
១៦- លោក ឡុត ចាន់ណា ប្រធានការិ.កសិកម្មស្រុកកូនមុំ ខេត្តរតនគិរី

១៧-	លោក ឌុល វុធ	ប្រធានការិ.កសិកម្មស្រុកអូរជុំ ខេត្តរតនគិរី
១៨-	លោក តួល នំ	ប្រធានគណៈកម្មការសហគមន៍ទំពួនភូមិល្អឺនក្រែន ស្រុកអូរជុំ ខេត្តរតនគិរី
១៩-	លោក ង៉ែន ភិន	ប្រធានគណៈកម្មការ សហគមន៍ទំពួន ភូមិឡាអ៊ិន ស្រុកកូនមុំ ខេត្តរតនគិរី
២០-	លោក សេង សុវណ្ណរ័ត្ននា	មន្ត្រី ក្រសួង រៀបចំដែនដីនគរូបនីយកម្ម និងសំណង់
២១-	លោក ជ្រិន ម៉េងហុង	មន្ត្រី ក្រសួង រៀបចំដែនដីនគរូបនីយកម្ម និងសំណង់
២២-	លោកស្រី លុន ពុធារី	មន្ត្រី ក្រសួង រៀបចំដែនដីនគរូបនីយកម្ម និងសំណង់
២៣-	លោកស្រី កែវ ភិរុណ	អនុ.នាយកដ្ឋានរដ្ឋបាល ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
២៤-	លោក ថៃ ម៉ូវ	អនុប្រធាននាយកដ្ឋាន ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
២៥-	លោក គិម គីណា	ប្រធានការិយាល័យរដ្ឋបាល មន្ទីរ ជនសស ខេត្តមណ្ឌលគិរី
២៦-	លោកស្រី ជា អមរា	មន្ត្រីមន្ទីរ ជនសស ខេត្តមណ្ឌលគិរី
២៧-	លោក លឹម សុខខេង	ប្រធានការិ. ជនសភ ស្រុកអូររាំង ខេត្តមណ្ឌលគិរី
២៨-	លោក យឹម វណ្ណា	ប្រធានការិ. ជនសភ ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី
២៩-	លោក ឆឹង ច័ន្ទបូ	ប្រធានការិ. ជនសភ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី
៣០-	លោក អឿ សំអុល	អនុប្រធានការិ. ជនសភ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី
៣១-	លោក ស្រ៊ុន វណ្ណនី	ប្រធានការិ. ជនសភ ស្រុកកោះញែក ខេត្តមណ្ឌលគិរី
៣២-	លោកប្រាក់ សុខធី	ប្រធានការិ. ជនសភ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី
៣៣-	លោក ទី សុផល	អនុប្រធានការិ. ជនសភ ស្រុកពេជ្រាដា ខេត្តមណ្ឌលគិរី
៣៤-	កញ្ញា ប្រាក់ ចន្ធី	បុគ្គលិកអង្គការ WCS
៣៥-	លោក ពួន ញ៉ក់	មេភូមិអណ្ដូងក្រឡឹង ខេត្តមណ្ឌលគិរី
៣៦-	លោក ប្លែវ ប៊ីល	ប្រធានគណៈកម្មការសហគមន៍ជនជាតិដើមភាគតិចព្នងភូមិអណ្ដូងក្រឡឹង ខេត្តមណ្ឌលគិរី
៣៧-	លោក ស៊ីម សាត	អនុប្រធានគណៈកម្មការសហគមន៍ជនជាតិដើមភាគតិចព្នងភូមិអណ្ដូងក្រឡឹង ខេត្តមណ្ឌលគិរី
៣៨-	លោកម្លូង ម៉ើក	អនុប្រធានគណៈកម្មការសហគមន៍ជនជាតិដើមភាគតិចព្នងភូមិអណ្ដូងក្រឡឹង ខេត្តមណ្ឌលគិរី
៣៩-	លោកស្រី អ៊ុក ដានែត	មន្ត្រីអគ្គ/ក្រុមប្រឹក្សា គោលនយោបាយដីធ្លី

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៤៤ .អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងព័ត៌មាន

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៥រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងអគារសិក្សា ចំនួន ០២ ខ្នង មាន០៧បន្ទប់ នៅសាលាបឋមសិក្សាបន្ទិចស្វាយ ឃុំព្រែកតានង់ ស្រុកកោះសូទិន ខេត្តកំពង់ចាម ចំណាយអស់ទឹកប្រាក់សរុបចំនួន ៤២.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ:

១-ឧកញ៉ា **ឡឹក សំបុណ្យ**

២-អ្នកស្រី **ឡឹក ណាវ៉ា**

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

១-លោក **ខិម សុភាព**

២-អ្នកស្រី **ខុល ឈីនដា**

៣-លោក **ខុល ឡាវី**

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៤៥ . អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ នៃអគ្គនាយកដ្ឋានរតនាគារជាតិ ចំនួន២៨រូប ដែលមានស្នាដៃល្អក្នុងការជួយឧបត្ថម្ភថវិកា កសាងអគារចំនួន ០២ ខ្នងនិងសមិទ្ធផលនានា ដល់កងពលតូចថ្មើរជើងលេខ ៥៣ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ និបឌិន្ទ:

១-	លោក	ថៅ	សុខមុនី	ប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក អគ្គនាយកដ្ឋានរតនាគារជាតិ
២-	លោក	ឆ៉ា	រុន	ប្រធាននាយកដ្ឋានអធិការកិច្ចរតនាគារ អគ្គនាយកដ្ឋានរតនាគារជាតិ
៣-	លោក	ខឹម	រិទ្ធីសែន	ប្រធាននាយកដ្ឋានចំណូល និងចំណាយថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ
៤-	លោក	ហៀង	សុខហួត	ប្រធាននាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានរតនាគារជាតិ
៥-	លោកជំទាវ	ហ៊ីន	គីមថាច	ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម
៦-	លោក	ឃឹម	សេងគ្រី	អនុប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក អគ្គនាយកដ្ឋានរតនាគារជាតិ
៧-	លោកស្រី	អ៊ូ	យ៉េកឡាង	អនុប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក អគ្គនាយកដ្ឋានរតនាគារជាតិ
៨-	លោកស្រី	អ៊ុំ	សុជាតិ	អនុប្រធាននាយកដ្ឋានចំណូល និងចំណាយថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ

៩-	លោក	ហ៊ីវ	បញ្ញាសិទ្ធិ	អនុប្រធាននាយកដ្ឋានគ្រប់គ្រងបេឡា និងបំណុល អគ្គនាយកដ្ឋានរតនាគារជាតិ
១០-	លោកស្រី	ប្រាក់	រមណី	អនុប្រធាននាយកដ្ឋានគ្រប់គ្រងបេឡា និងបំណុល អគ្គនាយកដ្ឋានរតនាគារជាតិ
១១-	លោក	សំកុល	សុខា	អនុប្រធាននាយកដ្ឋានរតនាគារថ្នាក់មូលដ្ឋាន អគ្គនាយកដ្ឋានរតនាគារជាតិ
១២-	លោក	កែវ	សុមិនា	សប្បុរសជន
១៣-	លោក	ប៉ក់	សុភាព	អនុប្រធាននាយកដ្ឋានរដ្ឋបាល និង បុគ្គលិក អគ្គនាយកដ្ឋានរតនាគារជាតិ
១៤-	លោកស្រី	អ៊ុំ	កញ្ញារ៉ោហ្វ្លីនន៍	ប្រធានការិយាល័យទី ២ នាយកដ្ឋានចំណូលចំណាយថវិកា
១៥-	លោក	ប៉ែន	ស្រេង	អនុប្រធានរតនាគារ ខេត្តកណ្តាល
១៦-	លោក	ហ៊ិន	តិចឡេង	អនុប្រធាន អធិការកិច្ចរតនាគារ អគ្គនាយកដ្ឋានរតនាគារជាតិ
១៧-	លោក	គិត	ម៉ុនហឿន	អនុប្រធាន គណនេយ្យ អគ្គនាយកដ្ឋានរតនាគារជាតិ

ខ-មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ សេនា:

១-	លោក	សួន	ដារ៉ារិទ្ធ	អនុប្រធានរតនាគារ ខេត្តព្រះសីហនុ
២-	លោក	ហួត	ទ៉ាន់ហាន	អនុប្រធានរតនាគារ ខេត្តរតនាគារកំពង់ឆ្នាំង
៣-	លោក	ជុំ	កោសលមុនី	ប្រធានការិយាល័យទី២ នាយកដ្ឋានគណនេយ្យ អគ្គនាយកដ្ឋានរតនាគារជាតិ

គ-មេដាយ មុនីសារាភ័ណ្ឌ ថ្នាក់ អស្សប្បន្ទិះ

១-	លោក	អ៊ិន	សារ៉ាត់	បុគ្គលិក អគ្គនាយកដ្ឋានរតនាគារជាតិ
២-	លោក	យៀន	សារិន	បុគ្គលិក អគ្គនាយកដ្ឋានរតនាគារជាតិ
៣-	លោក	ឌិន	ភង	បុគ្គលិក អគ្គនាយកដ្ឋានរតនាគារជាតិ
៤-	លោក	ជា	ឈាន	បុគ្គលិក អគ្គនាយកដ្ឋានរតនាគារជាតិ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និង មេបញ្ជាការកងទ័ពជើងគោក ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកញ្ញា ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៤៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមុខងារ នាយទាហាន

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និង ប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្រេច

មាត្រា១ : ត្រូវបានតែងតាំងមុខងារ នាយទាហាន នៃ កងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោមៈ

១-ឧត្តមសេនីយ៍ទោ **អ៊ុំ សារិទ្ធ** អត្តលេខ ០០១១០០ ជា មេបញ្ជាការរង និងជា នាយសេនាធិការ បញ្ជាការដ្ឋានអង្គរក្ស

២-ឧត្តមសេនីយ៍ទោ **យង់ សារិទ្ធ** អត្តលេខ ០០២៥៧០ ជា មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស

៣-ឧត្តមសេនីយ៍ទោ **ប៊ិច សុខី** អត្តលេខ ០០២៣៥០ ជា មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស

៤-ឧត្តមសេនីយ៍ទោ **អ៊ុក សុទ្ធសេន** អត្តលេខ ០០៣៩៩៩ ជា មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស

៥-ឧត្តមសេនីយ៍ទោ **នៅ សាវ៉ន** អត្តលេខ ០០៣៧៧៦ ជា មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស

៦-ឧត្តមសេនីយ៍ត្រី **អ៊ុច សិរីគុត្ត** អត្តលេខ ០១១៨១៣ ជា ស្នងការ ស្នងការដ្ឋានបុគ្គលិក-បណ្តុះបណ្តាល បញ្ជាការដ្ឋានអង្គរក្ស

៧-ឧត្តមសេនីយ៍ត្រី **កែវ អាន** អត្តលេខ ០០៥១៦៦ ជា ស្នងការ ស្នងការដ្ឋានស្រាវជ្រាវ-សន្តិសុខ បញ្ជាការដ្ឋានអង្គរក្ស

មាត្រា២ : រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងបណ្តាសមាសភាពដូចក្នុងមាត្រា ១ ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៥៧ អនក្រ.បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយ សហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់មេដាយ **សហមេត្រី ថ្នាក់មហាសេនា** ជូនដល់នាយនគរបាល និងនាយទាហានវៀតណាមចំនួន ០២ នាក់ នៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម បានរួមសហការល្អប្រសើរជាមួយនាយកដ្ឋាននគរបាលព្រំដែនទឹក ក្នុងការជួយឧបត្ថម្ភថវិកាសំរាប់កសាងអង្គភាពបង្ក្រាបបទល្មើសលើផ្ទៃសមុទ្រប្រចាំខេត្តព្រះសីហនុ និងទីបញ្ជាការវរៈសេនាតូចលេខ៤៣០ ប្រចាំខេត្តកែប ដូចមានរាយនាមខាងក្រោម ៖

១ លោកឧត្តមសេនីយ៍ត្រី NGUYEN QUANH LIET នាយកនគរបាលខេត្តគៀងយ៉ាង
២ លោកឧត្តមសេនីយ៍ត្រី LE VAN THI មេបញ្ជាការយោធា ខេត្តគៀងយ៉ាង

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៤៨ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១: ត្រូវបានប្រគល់ភារកិច្ចជូនលោក **គង់ ចំនួនទាសនា** អនុមន្ត្រីថ្នាក់លេខ ១៣ ឱ្យបំពេញមុខងារជាប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី ជំនួសលោក **ឆួន ស៊ីផាន់**។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៤៩ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការអនុញ្ញាតអោយមន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញអនុក្រឹត្យ ១១៦ អនក្រ.គត ចុះថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលអោយស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

-យោងតាមសំណើរបស់រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានអនុញ្ញាតអោយលោក **អ៊ុំ សុទ្ធី** ប្រធានផ្នែកទទួលបន្ទុកច្បាប់ពាណិជ្ជកម្ម និងធុរកិច្ចនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី ស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស រយៈពេល ០១ ឆ្នាំ លើកទី២ គិតចាប់ពីថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០១០ ដល់ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៥០ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដំឡើងឋានន្តរសក្តិ និងតែងតាំងមុខតំណែងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរសក្តិលោក **ឈុំ ចណ្ណារិទ្ធ** ពីឋានន្តរស័ក្តិអនុមន្ត្រី ថ្នាក់លេខ ៨ ទៅជា ឋានន្តរសក្តិវរមន្ត្រី ថ្នាក់លេខ ៩ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងសុខាភិបាល និងតែងតាំងមុខតំណែងជា អភិបាលរង ខេត្តបន្ទាយមានជ័យ ជំនួសលោក **សរ ចំរុង** ដែលបានទៅទទួលភារកិច្ចថ្មី ។

មាត្រា ២ : លោក **ឈុំ ចណ្ណារិទ្ធ** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីខាងលើ ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ខាងលើ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៤*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៥៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមាសស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែល ប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០២ (ពីរ) រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងអគារសាលាបឋមសិក្សា ០១ខ្នង ស្ថិតក្នុងភូមិស្វាយអំពារ ឃុំស្វាយអំពារ ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយនាម ខាងក្រោម ៖

១- លោក **ស៊ីនីឈី ហូកាអូ** (Mr. SHINICHI HOKAO) ថវិកា ២២.៨៣៥ ដុល្លារ

២- លោក **ថេតស៊ូរ៉ូ អ៊ីកេម៉ា** (Mr. TETSURO IKEMA) ថវិកា ២២.៥៦៥ ដុល្លារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ ឲ្យទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៥៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់មេដាយ **ការងារ** តាមលំដាប់ថ្នាក់ ជូនដល់នាយនគរបាលជាតិចំនួន ៣៦ នាក់ ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចថែរក្សា ការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សុវត្ថិភាព និងស្ថេរភាពសង្គម ដើម្បីបំរើផលប្រយោជន៍របស់ប្រទេសជាតិ និងប្រជាពលរដ្ឋបានល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយ មាស ការងារ ៖

១-	លោកឧត្តមសេនីយ៍ត្រី	គឹង	វណ្ណៈ	អត្តលេខ ៦៤៥៥៥	អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
២-	លោកវរសេនីយ៍ឯក	អ៊ិត	សិទ្ធី	អត្តលេខ ០៦៧៩	អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៣-	លោកវរសេនីយ៍ឯក	នង	សារី	អត្តលេខ ០៦៨២	អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៤-	លោកវរសេនីយ៍ឯក	ខាន់	ផល្លី	អត្តលេខ ១៥៨២៦	អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៥-	លោកវរសេនីយ៍ទោ	ឡុង	ស្រេង	អត្តលេខ ០៥៩៥៩	នាយការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៦-	លោកវរសេនីយ៍ទោ	សួន	ណារ៉ា	អត្តលេខ ០២៣៤៥	នាយការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៧-	លោកវរសេនីយ៍ទោ	ទូច	យុទ្ធា	អត្តលេខ ០៥៥២៥	នាយការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៨-	លោកវរសេនីយ៍ទោ	អេង	សាខន	អត្តលេខ ០១០៩៧	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៩-	លោកវរសេនីយ៍ទោ	ប៉ុល	សៀង	អត្តលេខ ០៦៤៤៤	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១០-	លោកវរសេនីយ៍ទោ	មិន	សោភ័ណ្ឌ	អត្តលេខ ០៦៥៩៩	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១១-	លោកវរសេនីយ៍ទោ	យិន	ប្រសិទ្ធ	អត្តលេខ ០២១៥៨	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

១២-	លោកវរសេនីយ៍ត្រី	ម៉ៅ	ច័ន្ទវិជ្ជា	អត្តលេខ ១៥៩៣៩	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១៣-	លោកវរសេនីយ៍ត្រី	ឡាយ	សុភី	អត្តលេខ ០៩៧៤២	នាយផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១៤-	លោកវរសេនីយ៍ត្រី	ហួន	សារិន	អត្តលេខ ០៤៧៩៦	នាយផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១៥-	លោកវរសេនីយ៍ត្រី	គន្ធ	ឫទ្ធី	អត្តលេខ ០៧៧៦៧	នាយផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១៦-	លោកអនុសេនីយ៍ឯក	ឡុង	វេជ្ជា	អត្តលេខ ០៥៥៧២	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១៧-	លោកអនុសេនីយ៍ឯក	ឡុង	គួង	អត្តលេខ ១២៦០២	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១៨-	លោកអនុសេនីយ៍ឯក	យ៉ែម	មុនីដារ៉ា	អត្តលេខ ០៥៥៣៦	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១៩-	លោកអនុសេនីយ៍ឯក	អ៊ុក	សារ៉េត	អត្តលេខ ០៥៥៧៤	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
២០-	លោកអនុសេនីយ៍ទោ	ចឹង	វណ្ណឌី	អត្តលេខ ៥៥០៩១	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
២១-	លោកអនុសេនីយ៍ទោ	តោ	តារា	អត្តលេខ ៣១៧៧៦	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
២២-	លោកអនុសេនីយ៍ត្រី	ឡៃ	ឡុងឌី	អត្តលេខ ៦២៤៩៨	មន្ត្រី នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
២៣-	លោកពលបាលឯក	ម៉ៅ	ដារីន	អត្តលេខ ៥៦៧៦៨	មន្ត្រី នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

ខ-មេដាយ ប្រាក់ ការងារ ៖

១-	លោកវរសេនីយ៍ត្រី	ម៉ែន	ចាន់ណា	អត្តលេខ ០៥៥៨២	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
២-	លោកវរសេនីយ៍ត្រី	សេង	សាន្ត	អត្តលេខ ០៥៥៥៩	នាយផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៣-	លោកវរសេនីយ៍ត្រី	សូ	ស៊ីណាត	អត្តលេខ ០៩៧៤៩	នាយផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៤-	លោកវរសេនីយ៍ត្រី	ឈឹម	ឈឿន	អត្តលេខ ០៣៦៣៧	នាយផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៥-	លោកវរសេនីយ៍ត្រី	ប៊ុន	រ៉ាវុធ	អត្តលេខ ៦៧៥៨៩	មន្ត្រី នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៦-	លោកអនុសេនីយ៍ឯក	ហាក់	សុគា	អត្តលេខ ០៧៧០១	នាយផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៧-	លោកអនុសេនីយ៍ឯក	វៃ	គុណ	អត្តលេខ ០៥៥៩៧	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៨-	លោកអនុសេនីយ៍ទោ	ឡុង	សំអឿន	អត្តលេខ ៣១៧៣៩	នាយរងផ្នែក នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
៩-	លោកអនុសេនីយ៍ត្រី	នូ	មន	អត្តលេខ ២៥៨៨២	មន្ត្រី នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១០-	លោកអនុសេនីយ៍ត្រី	លឹម	ថេងហេង	អត្តលេខ ៣១៧០១	មន្ត្រី នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
១១-	លោកអនុសេនីយ៍ត្រី	ហុក	ចិត្រា	អត្តលេខ ៣១៧៩៣	មន្ត្រី នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

គ-មេដាយ សំរិទ្ធ ការងារ ៖

១-	លោកអនុសេនីយ៍ត្រី	ព្រាប	កុសល	អត្តលេខ ៤០៦២៣	មន្ត្រី នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច
២-	លោកអនុសេនីយ៍ត្រី	សុខ	វិបុល	អត្តលេខ ៣៧៣៨៣	មន្ត្រី នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច

មាត្រា ២ ៈ

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៥៣ អនុក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

ស ម្រេ ច

មាត្រា ១ : តែងតាំងលោក **ចឹក សារេន** ជាទីប្រឹក្សាក្រសួងអភិវឌ្ឍន៍ជនបទ មានឋានៈស្មើ **អគ្គនាយករង** ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៥៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ម៉ែន ច័ន្ទសុខខេមរា** អនុមន្ត្រីថ្នាក់លេខ ១១ ឲ្យបំពេញមុខងារជាអធិការ នៃអធិការដ្ឋានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជំនួសលោក **ប៉ាល់ ច្រិច** ដែលត្រូវបានចូលនិវត្តន៍។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩៥៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០២គ្រឿង ជូនក្រុមហ៊ុន ដែលបានផ្តល់ថវិកាជួយកសាងអគារសិក្សា ចំនួន០២ខ្នង មាន០៦បន្ទប់ និងបង្គន់អនាម័យ ០១ខ្នង មាន០២បន្ទប់ នៅអនុវិទ្យាល័យសុវណ្ណគីរី ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ៖

១-ក្រុមហ៊ុន	WATAMI- TAIWAN	ថវិកា ចំនួន ៣២.០០០ ដុល្លារ
២-ក្រុមហ៊ុន	WATAMI- HONG KONG	ថវិកា ចំនួន ៣២.០០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៥៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **ទៅ ជួយ** សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយចាក់ដី និងធ្វើរបងសាលារៀនខ្មែរ ចិន ចុងវ៉ា ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់ចំនួន ១៥.០០០ ដុល្លារអាមេរិក ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៥៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនក្រុមទូរទស្សន៍ NIPPON TELEVISION NETWORK CORPORATION បានផ្តល់ថវិកាចំនួន ៤៧.៤៧១.៧០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០៤បន្ទប់ និងអាងទឹក០១ ជូនដល់សាលាបឋមសិក្សាគោកខ្នាំង ស្ថិតនៅឃុំរើល ស្រុកពួក ខេត្តសៀមរាប ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះអោយ ទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩៥៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន០១គ្រឿង ជូនក្រុមទូរទស្សន៍ **NIPPON TELEVISION NETWORK CORPORATION** បានផ្តល់ថវិកា ចំនួន ៨៧.១១៦.២៦ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា០១ខ្នង មាន០៣បន្ទប់ បង្គន់អនាម័យ ០៤បន្ទប់ និង អាងទឹក ០១ ជូនដល់សាលាបឋមសិក្សាប្រាសាទ ស្ថិតនៅឃុំព្រៃជ្រូក ស្រុកពួក ខេត្តសៀមរាប ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/ HR

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៩៥៩ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៨០០/១៥២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា
- យោងតាមការចាំបាច់

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ទេព ផល្លុន** ឲ្យបំពេញមុខងារជាប្រធានផ្នែកហិរញ្ញកិច្ច និងសម្ភារៈ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា មានឋានៈស្មើ **ប្រធាននាយកដ្ឋាន**។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ កញ្ញា ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :
